ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ០៥១/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី «ភាពជោគជ័យរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ស្ពឺ»

រសៀលថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តកំពង់ស្ពឺ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម វ៉ី សំណាង អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ**
- **រួមទាំងមន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តកំពង់ស្ពឺ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តកំពង់ស្ពឺ ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

### I. សេចក្តីផ្តើម

ខេត្តកំពង់ស្ពឺ មានផ្ទៃដីសរុបមានចំនួន ៦.៩៦៥,៦៣គ.ម២ ប្រជាជនសរុប ៩១៧.២៧៧នាក់ ស្មើនឹង ២២២.២៥៧គ្រួសារ។ ទំហំសេដ្ឋកិច្ចខេត្តមានចំនួនប្រមាណ ១.៦១២លានដុល្លារ ស្មើនឹង ៥,៩៥% នៃសេដ្ឋកិច្ចជាតិ។ ក្នុងឆ្នាំ២០២១ ប្រាក់ចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗមានចំនួន ១.៨៣៤ដុល្លាអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១៨ មានការកើនឡើងចំនួន ២,៥៦%។

## II. សមិទ្ធផលសំខាន់ៗ

ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក៏ដូចជាគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ និងពីគ្រប់មជ្ឈដ្ឋាន ប្រជាពលរដ្ឋក្នុងខេត្តទាំងមូល រដ្ឋបាលខេត្តកំពង់ស្ពឺ ទទួលបានការរីកចម្រើននូវគ្រប់វិស័យ ជាពិសេសរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមបានល្អប្រសើរ។ សមិទ្ធផលសំខាន់ៗ ដែលខេត្តសម្រេចបានរួមមាន៖

- **វិស័យគាំពារសង្គម៖** គិតមកដល់ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ ខេត្តបានអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដែលបានជួយដល់គ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម០២ឆ្នាំ គ្រួសារងាយរងហានិភ័យក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងគ្រួសារងាយរងហានិភ័យដែលរងផលប៉ះពាល់ធ្ងន់ដោយទឹកជំនន់ ចំណាយថវិកាសរុបចំនួន ១៣៧.០៩២.២៦៤.០០០រៀល។
- **វិស័យកសិកម្ម៖** ខេត្តមានផ្ទៃដីដាំដុះដំណាំស្រូវប្រាំង ដោយអនុវត្ត និងប្រមូលផលបានចំនួន ២.៤៩៨ហិកតា ទិន្នផលជាមធ្យមទទួលបាន ៣,៣៤២តោន ក្នុងមួយហិកតា និងដំណាំរួមផ្សំអនុវត្តបានចំនួន ២.១៨២ហិកតា។ ចំពោះស្រូវវស្សា អនុវត្តបានសរុបចំនួន ៥៨៩.២៧៧ហិកតា ទិន្នផលជាមធ្យមទទួលបាន ៣,១៩៥តោន ក្នុងមួយហិកតា និងដំណាំរួមផ្សំអនុវត្តបានចំនួន ១៣.៧៦៤ហិកតា។ ក្រៅពីដំណាំស្រូវ និងដំណាំរួមផ្សំផ្សេងទៀត ខេត្តក៏មានរោងចក្រកែច្នៃផលិតផលកសិកម្ម ដែលរួមចំណែកក្នុងការលើកស្ទួយសេដ្ឋកិច្ចខេត្តទាំងមូលចំនួន ១៣កន្លែង ក្នុងនោះ រោងចក្រកែច្នៃអំពៅ (ស្ករស)ចំនួន ០១កន្លែង រោងចក្រកែច្នៃដំឡូងមី ០១កន្លែង និងរោងចក្រដំណាប់ស្វាយ ១១កន្លែង ស្រូបយកកម្លាំងពលកម្មបានចំនួន ៤.៤២៤នាក់ ទទួលបានប្រាក់ចំណូលប្រមាណ ២០.១៨៤.៥០០ដុល្លាក្នុងមួយឆ្នាំ។
- **វិស័យឧស្សាហកម្ម៖** កំពង់ស្ពឺ ក៏ជាខេត្តមួយដែលពឹងផ្អែកខ្លាំងទៅលើការងារឧស្សាហកម្មនេះ ដោយបច្ចុប្បន្ននេះ ទូទាំងខេត្ត មានរោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន ៣៨៣កន្លែង ផ្តល់ការងារជូនប្រជាពលរដ្ឋប្រមាណ ១៥៥.៧៦១នាក់ ក្នុងនោះវិស័យវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងចំនួន ១៨៩កន្លែង មានកម្មករនិយោជិតសរុប ១៤៥.៣៩៩នាក់។ ជាមួយគ្នានេះ រោងចក្រធុនធំចំនួន ២២៩មូលដ្ឋាន ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ១៣២.៥០៣នាក់, រោងចក្រធុនតូចនិងមធ្យម និងសិប្បកម្មមានចំនួន ១.១៣០មូលដ្ឋាន ប្រាស់កម្លាំងពលកម្មសរុបចំនួន ១៤.៦២០នាក់ ស្រីចំនួន ៧.៧០០នាក់។

- **ការងារអភិវឌ្ឍន៍ជនបទ៖** ការផ្គត់ផ្គង់ថាមពលអគ្គិសនី ទឹកស្អាត និងអនាម័យជនបទ ត្រូវបានលើកកម្ពស់ ដោយបច្ចុប្បន្ននេះ ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ចំនួន ៩១.៨២៦គ្រួសារ ស្មើនឹង ៤១,៣១% និងមានបណ្តាញអគ្គិសនីចូលដល់ចំនួន ១.៣៦៧ភូមិ ស្មើនឹង៩៩,១៣% ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ចំនួន ៩២,២១%។ ជាមួយគ្នានេះ ខេត្តបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគម្រោង ODF និងត្រៀមក្នុងការប្រកាសថាជាខេត្តដែលបាន បញ្ចប់ការបន្ទោបង់ពាសវាលពាសកាលផងដែរ។
- **វិស័យទេសចរណ៍៖** ខេត្តមានរមណីយដ្ឋាន និងសហគមន៍ទេសចរណ៍សរុបចំនួន ២៥ ទីតាំង ដោយក្នុងរយៈពេល ៥ឆ្នាំនេះ មានភ្ញៀវទេសចរចូលទស្សនាតាមរមណីយដ្ឋាននានាចំនួន ១.៤២០.២៦៦នាក់ ក្នុងនោះភ្ញៀវទេសចរជាតិចំនួន ១.៣៧០.១៨១នាក់ និងភ្ញៀវអន្តរជាតិ ៥០.០៨៥នាក់។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្តកំពង់ស្ពឺ បានប្តេជ្ញាចិត្តនឹងបន្តខិតខំធ្វើការអភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធរបស់ខេត្ត ដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ធានាបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ជាពិសេសអភិវឌ្ឍវិស័យសំខាន់ៗ ដូចជាវិស័យកសិកម្ម វិស័យធនធានទឹក ប្រព័ន្ធធារាសាស្ត្រ ដែលបានជំរុញផលិតកម្មកសិកម្ម ទទួលបានផលជាអតិបរិមា និងបង្កើនការងារជូនប្រជាពលរដ្ឋ តាមរយៈការទាក់ទាញនូវការវិនិយោគបន្ថែមទៀត។ លើសពីនេះ បន្តយកចិត្តទុកដាក់ និងកែលម្អជាបន្តបន្ទាប់ លើការងារសង្គមកិច្ច ដើម្បីលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិតរបស់ប្រជាពលរដ្ឋ តាមរយៈការជំរុញវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធនានា ព្រមទាំងជំរុញយ៉ាងសកម្មនូវការកែទម្រង់អភិបាលកិច្ច ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ធានាបាននូវការបម្រើប្រជាពលរដ្ឋឱ្យបានកាន់តែល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣